ព្រះគម្ពីរសំរាប់កុមារ
សូមបង្ហាញជូន

# កូនប្រុសសំណព្វ
# ចិត្តបានក្លាយជា
# ទាសករ



និពន្ធដោយ៖ Edward Hughes

ធ្វើការពន្យល់ដោយ៖ Byron Unger; Lazarus Alastair Paterson

កែសម្រួលដោយ៖ M. Kerr; Sarah S.

បកប្រែដោយ៖ www.christian-translation.com

ផលិតដោយ៖ Bible for Children
www.M1914.org

©2023 Bible for Children, Inc.
អាជ្ញាប័ណ្ណ៖ លោកអ្នកមានសិទ្ធិក្នុងការថតចម្លង ឬបោះពុម្ពរឿងនេះបាន
តែលោកអ្នកមិនអាចយកវាទៅលក់បានទេ។

លោកអ៊ីសាក់ ពិតជាសប្បាយចិត្តខ្លាំងណាស់។ ចំពោះការវិលត្រឡប់
ត្រឡប់មកផ្ទះវិញរបស់លោកយ៉ាកុបជាកូន។ ទោះបីជា លោកអេសាវ
បានទទួលស្វាគមន៍យ៉ាងកក់ក្ដៅក្ដី ក៏មានម្ដងនោះលោកធ្លាប់ស្បថ
នឹងសម្លាប់លោកយ៉ាកុបចោលផង។ ប៉ុន្តែ កូនៗរបស់លោកយ៉ាកុប
មិន សប្បាយចិត្តជាមួយលោកយ៉ូសែប ដែលជា
ប្អូនប្រុសរបស់ខ្លួន និង ជាកូនសំណព្វចិត្ត
របស់ឪពុកខ្លួនឡើយ។



បងៗរបស់លោកយ៉ូសែបមានចិត្តច្រណែន និង ចងគំនុំជាមួយលោក
យ៉ាងខ្លាំង ពេលបានស្ដាប់សុបិន្តនិមិត្ត ដែលលោកយ៉ូសែបបានប្រាប់
ថា ៖ “សូមបងៗស្ដាប់សុបិនរបស់ខ្ញុំ គឺខ្ញុំបានយល់សប្តិឃើញយើង
ទាំងអស់គ្នាកំពុងតែចងកណ្ដាប់ស្រូវ នៅវាលស្រែ។



ស្រាប់តែកណ្ដាប់របស់ខ្ញុំងើបឈរឡើងយ៉ាងត្រង់ រីឯកណ្ដាប់របស់បងៗ
បានមកព័ទ្ធជុំវិញកណ្ដាប់ខ្ញុំ ហើយនាំគ្នាក្រាបថ្វាយបង្គំទៀតផង”។
សុបិន្តនិមិត្តនេះ មានន័យសម្ដៅថា យ៉ូសែបនឹងមានឋានៈដ៏សំខាន់
និងខ្ពស់ជាងបងៗរបស់លោក។





រីឯនៅក្នុងសុបិន្តទីពីររបស់លោក
យ៉ូសែប គឺលោកសុបិន្តឃើញ
ថា ដួងអាទិត្យ, ដួងច័ន្ទ និង
តារានិករណ៍ទាំងឡាយបាន
ក្រាបថ្វាយបង្គំលោក។ សូម្បីតែ
លោកយ៉ាកុបជាឪពុករបស់
លោក ក៏នសប្បាយចិត្តចំពោះ
ការដែលយ៉ូសែបបានលើកខ្លួន
ឡើង ខ្ពស់ជាងឪពុកម្តាយ នឹង
បងៗរបស់ខ្លួនដែរ។

ថ្ងៃមួយ លោកយ៉ាកុប បានចាត់យ៉ូសែបជាកូនឲ្យទៅសួរសុខទុក្ខបងៗ ដែលនៅឃ្វាលហ្វូងសត្វនៅទីវាល។ បងៗរបស់ លោកបានឃើញ លោកកំពុងធ្វើដំណើរមក គេនិយាយគ្នាថា ៖ “តោះយើងនាំគ្នាសម្លាប់ អាមេឃល់សប្តិនេះចោលទៅ”។ លោកយ៉ូសែប មិនបានដឹងថានឹង មានគ្រោះថ្នាក់នៅចំពោះមុខលោកសោះឡើយ។



លោករ៉ូបេន ជាបងច្បងមិនព្រមឲ្យគេសម្លាប់លោកយ៉ូសែបទេ។ លោកមានប្រសាសន៍ថា ៖ “កុំប្រហារជីវិតវាធ្វើអ្វី។ កុំបង្ហូរឈាមវាធ្វើអ្វី គឺគ្រាន់តែបោះវាទៅក្នុងអណ្ដូងនៅវាលរហោស្ថាននេះបានហើយ មិនបាច់សម្លាប់វាទេ”។ លោកមានប្រសាសន៍ ដូច្នេះ មកពីលោកចង់រំដោះយ៉ូសែបឲ្យរួចពីកណ្ដាប់ដៃរបស់បងនៅពេលយប់ ហើយនាំទៅជូនលោកឪពុកវិញ។



កាលលោកយ៉ូ
សែបបានទៅដល់
ហើយ បងៗរបស់លោក
បានចាប់លោក ហើយ
ដោះអាវបំពង់ដ៏ប្រណិត
របស់លោក ជាអាវដែល
ឪពុករបស់លោកបានធ្វើ
ឲ្យក្នុងនាមជាកូនសំណ
ព្វ។ បន្ទាប់មកគេបាន
យកលោកទៅឃុំនៅក្នុង
អណ្ដូងស្ងួតមួយ។



ក្នុងពេលដែលលោករ៉ូបេនមិនមានវត្តមាននោះ
គេក្រឡេកមើលឃើញជនជាតិពានិជ្ជករ
គ្រឿងក្រអូបមួយក្រុមធ្វើដំណើរ
យកគ្រឿងក្រអូបទៅលក់នៅស្រុកអេស៊ីប។
លោកយូដាដែលជាបងប្រុសរបស់លោក
មានប្រសាសន៍ថា។





“បើយើងសម្លាប់ប្អូនយើងចោល
តើបានចំណេញអ្វី នាំតែពិបាកលាក់
ឃាតកម្មនេះថែមទៀត។ តោះយើងលក់
វាអោយពួកអ៊ីស្មាអែលវិញ កុំសម្លាប់វាអី
ព្រោះវាជាប្អូនរបស់យើង
ជាសាច់ឈាមយើងដែរ”។





ពួកគេក៏ព្រមព្រៀង
គ្នាលក់លោកយ៉ូសែប
ក្នុងតម្លៃប្រាក់ម្ភៃស្លឹង។

លោកយ៉ូសែបបានចាកចេញទៅទាំងទឹកភ្នែក និង ភ័យខ្លាចយ៉ាងខ្លាំង
ព្រមទាំងអស់សង្ឃឹមយ៉ាងខ្លាំង ខណៈពេលដែលគេកញ្លក់លើកលោក
ដាក់អូដ្ឋនាំលោកទៅឆ្ងាយពីគ្រួសារ និង ស្រុកកំណើត។





បងៗ របស់លោកយ៉ូសែបបានប្រតិដ្ឋរឿងកុហកឪពុក
ដោយផ្ញើរអាវបំពង់ដ៏ប្រណិតនោះទាំងផ្ដាំថា “ពួកកូន
បានរកឃើញអាវនេះ សូមលោកឪពុកពិនិត្យមើល តើអាវ
នេះពិតជាអាវរបស់កូនលោកឪពុកមែន ឬមិនមែន?”។
លោកយ៉ាកុបបានជឿជាក់ទាំងស្រុងថា
សត្វសាហាវបានហែកកូនសំណព្វ
របស់លោកជាចំណីទៅហើយ។
លោកហែកសម្លៀកបំពាក់
និង កាន់ទុក្ខចំពោះមរណៈ
ភាពរបស់លោកយ៉ូសែប
ហើយគ្មាននរណាម្នាក់អាច
សម្រាលទុក្ខលោកបានឡើយ។

លោកយ៉ូសែបត្រូវបានគេនាំទៅដល់ស្រុកអេស៊ីប ប្រកបដោយ
ការភ័ខ្លាច និង ឯការបំផុត។ ប្រហែលងចិត្តរបស់លោកចង់ត្រ
ឡប់ទៅផ្ទះវិញណាស់។ ប៉ុន្តែលោកមិនអាចរកមធ្យោបាយដើម្បី
ត្រឡប់ទៅស្រុកវិញបានទេ។
លោកយ៉ូសែបត្រូវបានគេលក់
បន្តឲ្យទៅលោកបូទីផា ជាមន្ត្រីដ៏
សំខាន់មួយរូបនៃជនជាតិអេស៊ីប។
លោកបូទីផា ពេញចិត្តនឹងលោក
យ៉ូសែបខ្លាំងណាស់
ព្រោះការអ្វីដែលលោក
បានធ្វើសុទ្ធតែបានផលល្អទាំងអស់។



ថ្ងៃមួយ លោកប៉ូទីផាបានប្រាប់លោកយ៉ូសែបថា ៖ “អ្នកបានសម្រេចកិច្ចការបានយ៉ាងល្អ ព្រះជាអម្ចាស់គង់ជាមួយអ្នក ខ្ញុំចង់តែងតាំងអ្នកមើលការខុសត្រូវលើកទ្រព្យសម្បត្តិ និង ផ្ទះសម្បែងរបស់ខ្ញុំទាំងអស់ គឺអ្នកជាមេលើខ្ញុំបម្រើទាំងអស់របស់ខ្ញុំ”។



ដោយសារតែលោកយ៉ូសែប ព្រះជា
ម្ចាស់បានប្រទានពរដល់លោកបូទី
ផា មានទ្រព្យសម្បត្តិ និង ភោគផល
ជាបរិបូរ។ ពេលនេះ លោកយ៉ូសែប
ក្លាយជាមនុស្សដ៏សំខាន់ក៏ពិតមែន
តែលោកនៅតែទុកចិត្ត និង គោរព
បម្រើព្រះជាម្ចាស់យ៉ាងស្មោះត្រង់។
ប៉ុន្តែបញ្ហាក៏បានកើតឡើងដល់
លោកយ៉ូសែប។



ភរិយារបស់លោកប៉ូទីផា ជាស្ត្រីមិនល្អទេ។ នាងបានសុំឲ្យលោកយ៉ូសែប មកជំនួសតំណែងស្វាមីរបស់នាង។ លោកយ៉ូសែបបដិសេធ។ លោកនឹងមិនប្រព្រឹត្តអំពើបាបប្រឆាំងនឹងព្រះជាម្ចាស់ដោយប្រព្រឹត្តខុសឆ្គងជាមួយលោក
ប៉ូទីផាសោះឡើយ។



ខណៈដែលស្ត្រីនោះព្យាយាមបង្ខំលោកឲ្យប្រព្រឹត្តខុសសីលធម៌ជាមួយនាង លោកយ៉ូសែប បានរលាស់អាវរបស់ខ្លួន ហើយរត់គេចចេញ។ ប៉ុន្តែអាវធំរបស់លោកយ៉ូសែប ស្ថិតក្នុងដៃរបស់ស្ត្រីជាភរិយា លោកប៉ូទីផា។



នាងបានមួលបង្កាច់ប្រាប់លោកបូទីផាជាប្ដីថា ៖ “ទាសករជាតិហេប្រឺដែលបងបានយកមកនោះ វាមករករំលោភខ្ញុំ តែដោយខ្ញុំស្រែកហៅគេយ៉ាងខ្លាំង វាក៏ទុកអាវចោលនៅនឹងខ្ញុំ ហើយរត់ចេញទៅខាងក្រៅ”។

លោកបូទីផា ក្ដៅក្រហាយយ៉ាងខ្លាំង។ ប្រហែលលោកក៏ដឹងហើយថា ភរិយារបស់លោកនិយាយកុហកទេ។ ប៉ុន្តែលោកត្រូវតែធ្វើអ្វីម្យ៉ាង។ តើលោកនឹងសម្រេចចិត្តបែបណា?



លោកបូទីផា បានចាប់លោកយ៉ូសែបដាក់ឃុំក្នុងពន្ធនាគារ។ ថ្វីដ្បិតតែលោកត្រូវបានជាប់ឃុំដោយលោកមិនបានប្រព្រឹត្តខុសក្តី ក៏លោកមិនអារម្មណ៍ជូរចត់ ឬក្តីក្រហាយអ្វីដែរ។ ប្រហែលលោកយ៉ូសែបបានរៀនការឆ្លងកាត់គ្រាលំបាក មិនថា លោកនៅទីណាក្តី បើលោកលើកតម្កើងព្រះជាម្ចាស់ នោះព្រះអង្គនឹងលើកកិត្តយសលោកវិញដែរ ទោះបីជាលោកនៅក្នុងពន្ធនាគារក៏ដោយ។



កូនប្រុសសំណព្វចិត្តបានក្លាយជាទាសករ

រឿងមួយពីព្រះបន្ទូលរបស់ព្រះជាម្ចាស់,

អាចរកឃើញនៅក្នុងព្រះគម្ពីរ

លោកុប្បត្តិ ៣៧, លោកុប្បត្តិ ៣៩

“ការស្វែងយល់ព្រះបន្ទូលរបស់ព្រះអង្គ ធ្វើឲ្យមនុស្សភ្លឺស្វាង
ហើយធ្វើឲ្យអ្នកទន់ទាបមានប្រាជ្ញា។”
ទំនុកតម្កើង 119:130


ចប់

រឿងព្រះគម្ពីរនេះប្រាប់យើងពីព្រះជាម្ចាស់ដ៏អស្ចារ្យរបស់
យើងដែលបានបង្កើតយើងមក ហើយចង់អោយអ្នកស្គាល់ទ្រង់។

ព្រះអង្គជ្រាបថា យើងបានប្រព្រឹត្តអំពើអាក្រក់, ដែលទ្រង់ហៅការទាំងនោះថាជា អំពើបាប។ ទោសនៃអំពើបាបគឺសេចក្ដីស្លាប់, ប៉ុន្តែព្រះទ្រង់ស្រឡាញ់យើងខ្លាំងណាស់ ដល់ម្ល៉េះហើយបានជាទ្រង់បានចាត់ព្រះយេស៊ូដែលជាព្រះរាជបុត្រាតែមួយរបស់ព្រះអង្គអោយមកសុគតនៅលើឈើឆ្កាង ហើយបង់ថ្លៃនៃទោសនោះជំនួសយើង។ ព្រះយេស៊ូបានរស់ពីសុគតឡើងវិញ ហើយបានយាងត្រលប់ទៅស្ថានសួគ៌! ប្រសិនបើអ្នកជឿលើព្រះយេស៊ូ ហើយសុំទ្រង់អោយអភ័យទោសចំពោះអំពើបាបរបស់អ្នក, ទ្រង់នឹងលើកលែងទោសអោយអ្នក! ទ្រង់នឹងមក ហើយរស់ក្នុងចិត្តរបស់អ្នកឥឡូវនេះ, ហើយអ្នកនឹងរស់នៅជាមួយទ្រង់ជារៀងរហូត។

ប្រសិនបើអ្នកជឿថានេះជាការពិត, អ្នកត្រូវទូលទៅកាន់ព្រះអង្គថា៖ ឱព្រះយេស៊ូទូលបង្គំជឿហើយថាទ្រង់ជាព្រះ ហើយបានក្លាយជាមនុស្សម្នាក់មកដើម្បីសុគតជំនួសអំពើបាបរបស់ទូលបង្គំ, ហើយពេលនេះទ្រង់រស់ពីសុគតឡើងវិញ។ សូមទ្រង់យាងចូលក្នុងជីវិតរបស់ទូលបង្គំ ហើយអភ័យទោសចំពោះអំពើបាបរបស់ទូលបង្គំ ដើម្បីទូលបង្គំអាចមានជីវិតថ្មីនាពេលឥឡូវនេះបាន ហើយថ្ងៃមួយទូលបង្គំនឹងទៅនៅជាមួយទ្រង់ជារៀងរហូត។ សូមជួយទូលបង្គំអោយគោរពទ្រង់ហើយរស់នៅសំរាប់ទ្រង់ដូចជាបុត្ររបស់ទ្រង់។ អាម៉ែន។

សូមអានព្រះគម្ពីរ ហើយអធិដ្ឋានទៅព្រះជារៀងរាល់ថ្ងៃ!   យូហាន ៣:១៦